**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០២.២៣៧/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

# សន្និសីទសារព័ត៌មាន ប្រកាសផ្សាយបញ្ជីបេក្ខជនផ្លូវការ ចំនួនបេក្ខជនឈរឈ្មោះបោះឆ្នោត លទ្ធផលបណ្តោះអាសន្ននៃការចែកប័ណ្ណព័ត៌មានដែលត្រូវបានបោះពុម្ព

នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំសន្និសីទសារព័ត៌មាន ប្រកាសផ្សាយអំពីបញ្ជីបេក្ខជនផ្លូវការ ចំនួនបេក្ខជនឈរឈ្មោះបោះឆ្នោត លទ្ធផលបណ្តោះអាសន្ននៃការចែកប័ណ្ណព័ត៌មាន និងសន្លឹកឆ្នោតដែលត្រូវបានបោះពុម្ព ។

ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក គ.ជ.ប បានមានប្រសាសន៍ក្នុងសន្និសីទនោះថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានគណបក្សនយោបាយចំនួន ១២ បានចូលរួមប្រកួតប្រជែង ហើយបេក្ខជនឈរឈ្មោះបោះឆ្នោត សរុបទូទាំងប្រទេសមានចំនួន ១០២.២៦៦នាក់ ក្នុងនោះមានស្ត្រីសរុប ចំនួន ២១.៨៤០នាក់ ។ ឯកឧត្តម បានឱ្យដឹងផងដែរនូវលទ្ធផលបណ្តោះអាសន្ននៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតថា រហូតមកដល់ពេលនេះ គ.ជ.ប បានផ្តល់ប័ណ្ណព័ត៌មានជូនអ្នកបោះឆ្នោត បានចំនួន ៣.៩៥០.៨៥៩ នាក់ ស្មើនឹង ៥០.៦៦% ។

ជាមួយគ្នានេះ ឯកឧត្តម ក៏បានបញ្ជាក់ថា ចំពោះដំណើរការផលិតសន្លឹកឆ្នោតនោះ គ.ជ.ប បានផលិតរួចរាល់ហើយ នូវសន្លឹកឆ្នោតចំនួន ៧ខេត្ត ហើយបានដឹកជញ្ជូនទៅរក្សាទុកនៅឃ្លាំង គ.ជ.ប កាលពីថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ នឹងត្រៀមធ្វើការបែងចែកសន្លឹកឆ្នោតទៅ គខ/កប ចាប់ពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៧ ខាងមុខនេះ ។

ពាក់ព័ន្ធនឹងការបោះពុម្ពសន្លឹកឆ្នោត មានមតិខ្លះបានលើកឡើងថា គ.ជ.ប មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ប្រចាំការនៅក្នុងទីតាំងរោងពុម្ព ដែលត្រូវផលិតសន្លឹកឆ្នោតនោះ ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានបំភ្លឺថា ការបោះពុម្ពសន្លឹកឆ្នោតជាការទទួលខុសត្រូវរបស់ គ.ជ.ប និងម្ចាស់រោងពុម្ព ។ ឯកឧត្តម បានលើកឧទាហរណ៍ថា កាលពីឆ្នាំ ១៩៩៨ សន្លឹកឆ្នោតត្រូវបានបោះពុម្ពនៅប្រទេស ញូហ្សេលែន ហើយមិនមានអ្នកសង្កេតការណ៍ណាមួយនៅប្រចាំការឡើយ ។ ឯកឧត្តម បានសង្កត់ធ្ងន់ថា អ្នកសង្កេតការណ៍ដែលត្រូវពិនិត្យមើលនោះ គឺនៅឯការិយាល័យបោះឆ្នោត ព្រោះនៅថ្ងៃខាងមុខ សន្លឹកឆ្នោតត្រូវដឹកទៅការិយាល័យបោះឆ្នោត ហើយនៅថ្ងៃបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត នឹងត្រូវបង្ហាញអំពីសន្លឹកឆ្នោតដល់ភ្នាក់ងារ និងអ្នកសង្កេតការណ៍ មុនចាប់ផ្តើមបោះឆ្នោតនោះ រួចហើយធ្វើការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅនឹងការិយាល័យបោះឆ្នោតនោះតែម្តង ។

ជាមួយគ្នានេះ អ្នកសារព័ត៌មានបានលើកឡើងថា មានការរើសអើង ក្នុងការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការខុសឈ្មោះអ្នកបោះឆ្នោតក៏វិតណា ទើបអាចបោះឆ្នោតបាន ?

ឯកឧត្តម អគ្គលេខាធិការ បានមានប្រសាសន៍ថា ការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនេះ មានការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល គឃ/សប ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិពាក់ព័ន្ធ "ការចោទប្រកាន់ថាមានការរើសអើង មិនមែនទើបតែពេលនេះទេ ប៉ុន្តែយើងត្រូវមើលលទ្ធផលនៃការចែកប័ណ្ណ រយៈពេល ២សប្តាហ៍ យើងផ្តល់ប័ណ្ណជូនអ្នកបោះឆ្នោតជាង ៥០%" ម្យ៉ាងទៀត អ្នកបោះឆ្នោតក៏អាចបោះឆ្នោតបានដែរ ប្រសិនបើគាត់មិនបានទទួលប័ណ្ណព័ត៌មាននេះ ហើយគាត់មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនោះ ។ ចំពោះករណីខុសឈ្មោះ គ.ជ.ប បានចេញសេចក្តីណែនាំរួចហើយ ដល់ គឃ/សប គកប ឱ្យផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោត ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណឱ្យបានត្រឹមត្រូវនៅពេលបោះឆ្នោត ប្រសិនបើនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត មានឈ្មោះអ្នកបោះឆ្នោតដូចគ្នា ឬស្រដៀងគ្នា "ចាន់ ឬច័ន្ទ, ចិត្ត ឬចិត្រ..." ត្រូវផ្ទៀងផ្ទាត់ទិន្នន័យដទៃទៀត ដើម្បីឱ្យដឹងថា ឈ្មោះណាមួយជារបស់សាមីខ្លួនពិតប្រាកដ ។ ប្រសិនបើឈ្មោះនោះ ជាឈ្មោះរបស់អ្នកបោះឆ្នោតណាម្នាក់ពិតប្រាកដ ប៉ុន្តែមានខុសអក្ខរាវិរុទ្ធ ឬខុសទិន្នន័យបន្តិចបន្តួច ត្រូវអនុញ្ញាតឱ្យគាត់បោះឆ្នោត ។ បច្ចុប្បន្ន គ.ជ.ប កំពុងតែរៀបចំចេញសេចក្តីណែនាំលម្អិតថែមទៀត ទាក់ទងនឹងករណីឈ្មោះអ្នកបោះឆ្នោតនេះ ។